# តារាងស្តីពីព័ត៌មានរបស់គម្រោង

លេខPIP : 1202

(សម្រាប់បំពេញដោយក្រសួងផែនការ)

## ព័ត៌មានមូលដ្ឋានអំពីគម្រោង

*(ត្រូវបំពេញគ្រប់ចំណុចទាំងអស់)*

## ផ្នែក ក

១. ឈ្មោះគម្រោង : ការបញ្រ្ជាបការគ្រប់គ្រងធនធានធម្មជាតិទៅក្នុងតំបន់ទេសភាពនៃព្រៃធម្មជាតិ និងផលិតភាពធម្មជាតិនៅតំបន់ភាគខាងជើងនៃប្រទេសកម្ពុជា (INRM)

២. កាលបរិច្ឆេទគម្រោង

| | |
|---|---|
| កាលបរិច្ឆេទចាប់ផ្តើមគម្រោង | 27/07/20 |
| កាលបរិច្ឆេទបញ្ចប់គម្រោង | 26/06/25 |

៣. ចំណាយគម្រោងសរុប $3,540,320

៤. ស្ថាប័នទទួលខុសត្រូវ ក្រសួងបរិស្ថាន

| | |
|---|---|
| RESPONSIBLE UNIT | Department of Biodiversity, the General Directorate of Policy and Strategy |
| អង្គភាពទទួលខុសត្រូវ | នាយកដ្ឋានជីវៈចម្រុះនៃ អគ្គនាយកដ្ឋានគោលនយោបាយនិងយុទ្ធសាស្ត្រ |

៥. ស្ថានភាពគម្រោង គម្រោងកំពុងដំណើរការ

ព័ត៌មានលម្អិតអំពីគម្រោង

៦. ប្រភេទគម្រោង ៖ គម្រោងជំនួយបច្ចេកទេស

៧. ប្រភពហិរញ្ញប្បទាន៖ ជំនួយឥតសំណង

៨. មុំនៃគោលនយោបាយក្នុងយុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១ ដែលគម្រោងស្ថិតនៅ

មុំទី៥- ការធានាចីរភាពបរិស្ថាន និងការរៀបចំខ្លួនឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ ព្រមទាំងការលើកកម្ពស់សេដ្ឋកិច្ចបៃតង

៩. ការចូលរួមចំណែករបស់គម្រោងក្នុងការសម្រេចបានគោលនយោបាយអាទិភាពខាងលើ

គម្រោង INRM ចូលរួមចំណែកសម្រេចយុទ្ធសាស្ត្រអាទិភាព និងទស្សនវិស័យ នៃយុទ្ធសាស្ត្រ និងផែនការសកម្មភាពជាតិស្តីពីជីវៈចម្រុះ (NBSAP) ឆ្ពោះទៅឆ្នាំ២០៣០។ គោលដៅរបស់យុទ្ធសាស្ត្រ និងផែនការសកម្មភាពជាតិស្តីពីជីវៈចម្រុះ (NBSAP) ដែលគាំទ្រដោយគម្រោង INRM នេះ រួមមានៈ ក) គោលដៅទី១ ការកំណត់មូលហេតុ ចម្បងនៃការបាត់បង់ជីវៈចម្រុះ តាមរយៈការកាត់បន្ថយសម្ពាធដោយផ្ទាល់ និងបង្អាករការធ្លាក់ចុះនៃធនធាន ជីវៈចម្រុះក្នុងតំបន់ការពារធម្មជាតិ ខ)គោលដៅទី២ ដំណោះស្រាយសមស្របចំពោះជម្លោះរវាងការអភិរក្ស និងការអភិវឌ្ឍ គ)គោលដៅទី៣ អភិរក្សតំបន់ការពារធម្មជាតិដែលមានប្រព័ន្ធអេកូឡូស៊ីសំខាន់ៗ ឃ)គោលដៅទី៤ លើកកម្ពស់ការអភិរក្សជីវៈចម្រុះ និងការអភិវឌ្ឍ នៅកម្រិតមួយដែលធនធានពន្ធុ ប្រភេទ និងប្រព័ន្ធអេកូឡូស៊ី អាចទ្រទ្រង់បាន និង ង)គោលដៅទី៧ ផលប្រយោជន៍ ដែលទទួលបានពីធនធានជីវៈចម្រុះ និងសេវាកម្មប្រព័ន្ធអេកូឡូស៊ី គួរត្រូវបានបែងចែកដោយសមភាព និងសមធម៌ជាមួយសហគមន៍មូលដ្ឋាន។ ជាងនេះទៅទៀត គម្រោងនេះ នឹងចូលរួមសម្រេចបាននូវគោលដៅអាជី (Aichi Targets) ជាពិសេសគោលដៅយុទ្ធសាស្ត្រ B (ការកាត់បន្ថយសម្ពាធផ្ទាល់ទៅលើធនធានជីវៈចម្រុះ និងលើកកម្ពស់ការប្រើប្រាស់ដោយនិរន្តរភាព) និងគោលដៅយុទ្ធសាស្ត្រ C (ធ្វើឱ្យប្រសើរឡើងនូវស្ថានភាពធនធានជីវៈចម្រុះ តាមរយៈការការពារភាពសម្បូរបែបនៃប្រព័ន្ធអេកូឡូស៊ី ប្រភេទ និង ធនធានពន្ធុ)។ គម្រោងINRMនេះ ក៏ចូលរួមចំណែកសម្រេចបាននូវគោលដៅអភិវឌ្ឍន៍ដោយចីរភាព (SDG) ពិសេសគោលដៅទី២ ស្តីពីការបញ្ចប់សេចក្តីស្រេកឃ្លាន សម្រេចបានសុវត្ថិភាពចំណីអាហារ និងបង្កើនអាហារូបត្ថម្ភ និងលើកកម្ពស់ និរន្តរភាពកសិកម្ម និងគោលដៅទី១៥ ស្តីពីការការពារ ស្តារ និងលើកកម្ពស់ការប្រើប្រាស់ប្រព័ន្ធអេកូឡូស៊ីជីគោក និងគ្រប់គ្រងព្រៃឈើប្រកបដោយនិរន្តរភាព ការប្រយុទ្ធប្រឆាំងនឹងរហោស្ថានកម្ម បញ្ឈប់ការធ្វើឱ្យមានឱនភាពដី និងបញ្ឈប់ការបាត់បង់ជីវៈចម្រុះ។
គម្រោងនេះនឹងរួមចំណែកដល់ការធ្វើបច្ចុប្បន្នភាព NBSAP ដើម្បីឱ្យប្រទេសកម្ពុជាបានចូលរួមអនុវត្តពេញលេញនូវ"ក្របខណ្ឌការងារជីវៈចម្រុះសកល គួនមីង-ម៉ុងរ៉េអាល់"។

**១០. ការគាំទ្រដល់គោលនយោបាយអភិវឌ្ឍន៍ វិស័យឧស្សាហកម្មកម្ពុជា**

តើគម្រោងនេះគាំទ្រដល់ការអនុវត្តគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជាដែរឬទេ? មិនគាំទ្រ

**១១. វិស័យ** (សូមប្រើវិស័យ អនុវិស័យ ដែលមានចែងក្នុងផ.យ.អ.ជ.)

បរិស្ថាន និងការអភិរក្ស

**១២. ទីតាំងអនុវត្តគម្រោង** (ពិពណ៌នាពីទីតាំងដែលត្រូវអនុវត្តគម្រោង)

សៀមរាប, ព្រះវិហារ, កំពង់ធំ,

**១៣. គោលបំណងរបស់គម្រោង** (ពិពណ៌នាគោលបំណងចម្បងៗរបស់គម្រោង)

គម្រោងINRM មានគោលបំណងគាំទ្រដល់ការអភិរក្ស និងការប្រើប្រាស់ធនធានធម្មជាតិ ជីវៈចម្រុះ និងសេវាកម្មប្រព័ន្ធអេកូឡូស៊ី នៅតំបន់ទេសភាពភាគខាងជើងនៃប្រទេសកម្ពុជាប្រកបដោយនិរន្តរភាព។

**១៤. ការពិពណ៌នាអំពីគម្រោង** (ពិពណ៌នាអំពីសមាសភាគទាំងអស់របស់គម្រោង)

គម្រោងINRM ត្រូវបានអនុម័តពីនាយកប្រតិបត្តិមូលនិធិបរិស្ថានពិភពលោក (GEF CEO) កាលពីខែមិថុនា ឆ្នាំ២០២០ និងបានចាប់ផ្តើមដំណើរការគម្រោងជាផ្លូវការកាលពីថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០២០។ គម្រោងនេះ មានរយៈពេល៥ឆ្នាំ និងសង្ឃឹមថាបញ្ចប់ក្នុងខែមិថុនា ឆ្នាំ២០២៥។ ក្រសួងបរិស្ថាន ជាអ្នកអនុវត្តគម្រោង INRM ផ្ទាល់ និងសហការយ៉ាងជិតស្និតជាមួយកម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ (UNDP) និងដៃគូអនុវត្តន៍គម្រោងផ្សេងទៀត ទាំងនៅថ្នាក់ជាតិ និងក្រោមជាតិ។ គម្រោង នេះទទួលបានថវិកាពីមូលនិធិបរិស្ថានពិភពលោក ចំនួន USD 3,340,320 និងបដិភាគ(co-financing commitments) សរុបចំនួនUSD 10,200,000 ពី UNDP (USD 200,000) និងរាជរដ្ឋាភិបាលកម្ពុជា (USD 10,000,000)។ គម្រោង INRM កំពុងត្រូវបានអនុវត្តន៍ក្រោមសមាសភាគដែលបំពេញគ្នាទៅវិញទៅមកចំនួន ៣ គឺ:

សមាសភាគទី១: សមត្ថភាពស្ថាប័ន និងប្រព័ន្ធ សម្រាប់ការបញ្រ្ជាបការគ្រប់គ្រងតំបន់ទេសភាព

សមាសភាគទី២: ការគ្រប់គ្រងតំបន់ការពារធម្មជាតិ និងទីជម្រាលនៅជុំវិញ តំបន់ទេសភាពផលិតភាពតំបន់ប្រើប្រាស់ច្រើនយ៉ាង នៅភាគខាងជើងប្រទេសកម្ពុជា

សមាសភាគទី៣: ការគ្រប់គ្រងចំណេះដឹង បញ្ជ្រាបយេនឌ័រ ការសិក្សា និងការពិនិត្យតាមដានវាយតម្លៃ។

**១៥. យុត្តិកម្មលើគម្រោង** (បង្ហាញពីហេតុផលថាហេតុអ្វីបានជាគម្រោងនេះត្រូវបានជ្រើសរើស)

កំណើនតម្រូវការព្រៃឈើ ផ្ទៃដីដាំដំណាំ និងការដាំដំណាំឯកវប្បកម្ម ផលិតផលកសិកម្មនិងសត្វព្រៃ យ៉ាងកំហុក រួមជាមួយការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ និងការដឹកជញ្ជូននាពេលថ្មីៗនេះ បាននឹងកំពុងធ្វើឱ្យមានការផ្លាស់ប្តូរទេសភាព យ៉ាងលឿន ដោយបន្សល់ទុកនូវកត្តាគំរាមកំហែងយ៉ាងច្រើន ដល់ជីវៈចម្រុះ និងប្រព័ន្ធអេកូឡូស៊ី។ជាដំណោះស្រាយចំពោះកត្តាគំរាមកំហែងខាងលើ គម្រោង INRM ត្រូវបានបង្កើតឡើងក្នុងបំណងរួមចំណែក ការអភិវឌ្ឍសេដ្ឋកិច្ចសង្គមប្រកបដោយសុខដុមរមនា ការបង្កើនផលិតភាពផលិតកម្ម និងផ្ទៃដីកសិកម្ម និងការលើកកម្ពស់ជីវភាពប្រជាសហគមន៍នៅក្នុងតំបន់ភាគខាងជើងនៃប្រទេសកម្ពុជា។ ដូច្នេះដើម្បីសម្រេចបាននូវគោលបំណងរួមរបស់គម្រោង សកម្មភាពជាច្រើនកំពុងត្រូវបានអនុវត្តន៍ ដើម្បីពង្រឹង គោលនយោបាយ និងសមត្ថភាពស្ថាប័នគ្រប់ភាគីពាក់ព័ន្ធទាំងនៅថ្នាក់ជាតិ និងក្រោមជាតិ សំដៅឆ្ពោះទៅរក ការបញ្រ្ជាបនូវការអភិរក្ស ការការពារ និងការគ្រប់គ្រងជីវៈចម្រុះ ធនធានធម្មជាតិ និងសេវាកម្មប្រព័ន្ធអេកូឡូស៊ី ទៅក្នុងផែនការអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គមរបស់ខ្លួន។

**១៦. ផលប្រយោជន៍របស់គម្រោង** (រៀបរាប់ពីអ្នកដែលនឹងទទួលប្រយោជន៍ផ្ទាល់និងមិនផ្ទាល់ពីការអនុវត្តគម្រោង)

ផលប្រយោជន៍ជាច្រើន ដែលទទួលបានពីការការពារតំបន់ទេសភាព តាមរយៈគម្រោង INRM រួមមាន៖ ការអភិរក្សប្រភេទវងការគំរាមកំហែងសាកលប្រកបដោយប្រសិទ្ធភាពខ្ពស់ ការគ្រប់គ្រងធនធានធម្មជាតិមានភាពប្រសើរឡើង និងការធានាបាននូវការការពារសេវាកម្មប្រព័ន្ធអេកូឡូស៊ី។ ជារួមគម្រោងនេះ មានគោលបំណងពិសេសលើកកម្ពស់ ការគ្រប់គ្រងតំបន់ការពារធម្មជាតិដោយធានាបាននូវនិរន្តរភាពថវិកា ការបង្កើនផលិតភាពដីកសិកម្ម និងផលិតផល និងលើកកម្ពស់ជីវភាពប្រជាសហគមន៍។ នៅពេលបញ្ចប់គម្រោង យ៉ាងហោចណាស់៖ ក). ផ្ទៃដីសហគមន៍តំបន់ការពារធម្មជាតិ និងសហគមន៍ព្រៃឈើចំនួន 1,500ហិចតា ស្ថិតក្រោមការគ្រប់គ្រងប្រសើរជាងមុន ដែលអាចវាស់វែងបានតាមរយៈ ការធ្វើបច្ចុប្បន្នភាពនៃផែនការគ្រប់គ្រង ការពិនិត្យឡើងវិញនូវកិច្ចព្រមព្រៀងដែលបញ្ជាក់អំពីការប្តេជ្ញាក្នុងការអភិរក្ស ការបង្កើតឱ្យមានប្រព័ន្ធត្រួតពិនិត្យតាមដាន ដើម្បីវាយតម្លៃប្រសិទ្ធិភាពនៃការគ្រប់គ្រង ការបណ្តុះបណ្តាលប្រជាសហគមន៍អំពីសកម្មភាពនៃការគ្រប់គ្រងធនធានធម្មជាតិ និងការផ្តល់ថវិកាសមស្របសម្រាប់អនុវត្តផែនការគ្រប់គ្រង ខ).យ៉ាងហោចណាស់មនុស្ស 5,000នាក់ ដែលក្នុងនោះ 30% ជាស្ត្រីនឹងទទួលបានផលប្រយោជន៍អំពីការ អនុវត្តការគ្រប់គ្រងធនធានធម្មជាតិ ឱ្យមានភាពប្រសើរឡើង ជីវភាពប្រជាសហគមន៍ និងការអភិវឌ្ឍជំនួញខ្នាតតូចមានភាពប្រសើរឡើង ដែលជាមធ្យមមាន ប្រាក់ចំណូលកើនឡើង 15% ពីសកម្មភាពកសិកម្ម។

**១៧. ការសិក្សាសមិទ្ធិលទ្ធភាព**

| | |
|---|---|
| តើគម្រោងនេះតម្រូវឲ្យមានការសិក្សាសមិទ្ធិលទ្ធភាពដែរ ឬទេ? | **គ្មាន** |
| ប្រសិនបើត្រូវការ តើការសិក្សាសមិទ្ធិលទ្ធភាព បានរៀបចំហើយឬនៅ? | **មិនទាន់ចាប់ផ្តើម** |

**១៨. ផលប៉ះពាល់ផ្នែកបរិស្ថាននិងសង្គម** (ពិពណ៌សង្ខេបពីផលប៉ះពាល់របស់គម្រោងលើប្រជាជននិងបរិស្ថានជុំវិញ ប្រសិនបើមាន។ តើគម្រោងនេះនឹងជួយដល់ការកាត់បន្ថយភាពក្រីក្រដែរឬទេ?)

តាមរយៈគម្រោង INRM ផលប៉ះពាល់ផ្នែកបរិស្ថាន និងសេដ្ឋកិច្ចសង្គមក្នុងរយៈពេលវែង គឺៈ

១.) ការលើកកម្ពស់ការគ្រប់គ្រងប្រភពទឹក កសិកម្ម ព្រៃឈើ ទេសចរណ៍ធម្មជាតិ និងសកម្មភាព សេដ្ឋកិច្ចផ្សេងៗទៀតទាំងនៅក្នុងនិងក្រៅតំបន់ទេសភាពធម្មជាតិប្រកបដោយនិរន្តរភាព

២.) ការធ្វើឱ្យប្រសើរឡើងនូវផែនការ បទដ្ឋានគតិយុត្ត ការអនុវត្តច្បាប់ និងការតាមដាន ដើម្បីពង្រឹងប្រសិទ្ធិភាពនៃការគ្រប់គ្រងធនធានធម្មជាតិនៅក្នុងតំបន់ទេសភាពធម្មជាតិ

៣.) ការកាត់បន្ថយកត្តាគំរាមកំហែងដោយផ្ទាល់ដល់ជីវៈចម្រុះ ប្រព័ន្ធអេកូឡូស៊ី និងសេវាកម្មរបស់វា។

**១៩. ការប្រែប្រួល អាកាសធាតុ**

ក. តើសកម្មភាព ឬធាតុចេញរបស់គម្រោងទាក់ ទងនឹងការប្រែប្រួលអាកាសធាតុ ឬទេ? **មាន**

ប្រសិនបើទាក់ទងនឹងការប្រែប្រួលអាកាស ធាតុ សូមជ្រើសរើស **ទាំងពីរ**

ខ. តើគម្រោងមានភាពទាក់ទងនឹងការប្រែប្រួលអាកាសធាតុកម្រិតណា?

សូមជ្រើសរើសវិស័យដែលទាក់ទងនឹងការប្រែប្រួលអាកាសធាតុរបស់គម្រោងនិងបំពេញការចូលរួមចំណែកនៃចំណាយដែលទាក់ទងនឹងការប្រែប្រួលអាកាសធាតុរបស់គម្រោងធៀបនឹងតម្លៃគម្រោងសរុប។

| វិស័យដែលទាក់ទងនឹងការប្រែប្រួលអាកាសធាតុ | ភាគរយ | ភាពទាក់ទងនឹងការប្រែប្រួលអាកាសធាតុ |
|---|---|---|
| **១១. ជីវៈចម្រុះនិងការអភិរក្ស** | 30 | **ទាក់ទងតិចតួច** |

**២០. ការកាត់បន្ថយ ហានិភ័យ និង គ្រោះមហន្តរាយ**

តើសកម្មភាព ឬធាតុចេញរបស់គម្រោងទាក់ទងនឹងការកាត់បន្ថយហានិភ័យ និងគ្រោះមហន្តរាយដែរឬទេ? **មាន**

ប្រសិនបើ ទាក់ទងនឹងការកាត់បន្ថយហានិភ័យនិងគ្រោះមហន្តរាយ សូមជ្រើសរើស **ការកាត់បន្ថយ**

**២១. ការវិភាគយេនឌ័រ** (តើគម្រោងនេះមានផលប៉ះពាល់ដល់តួនាទីរបស់បុរសនិងស្ត្រីក្នុងទីតាំងរបស់គម្រោងនេះដូចម្តេច? តើស្ត្រីនឹងត្រូវចូលរួមយ៉ាងសកម្មក្នុងការអនុវត្តគម្រោងនេះដែរឬទេ?)

គម្រោងនេះ កំពុងទទួលបានការគាំទ្រយ៉ាងសកម្មពីក្រសួងបរិស្ថាន និងកិច្ចការនារី ដើម្បីធានាបានថាសមភាពយេនឌ័រ ត្រូវបានបញ្ជ្រាបទៅក្នុងគោលនយោបាយ បទដ្ឋានគតិយុត្ត គោលការណ៍ និងការអនុវត្តនានា ដែលពាក់ព័ន្ធនឹងការគ្រប់គ្រងធនធានធម្មជាតិ និងជីវៈចម្រុះ តាមបែបសមាហរណ៍កម្ម នៅក្នុងប្រទេសដែលជាប្រយោជន៍ដល់ស្ត្រីស្មើៗគ្នា។ ជាងនេះទៀត គម្រោងកំពុងផ្តល់ឱកាសស្មើៗគ្នា ដល់បុរស និងស្ត្រីដែលជាអ្នករៀបចំគោលនយោបាយ អ្នកធ្វើសេចក្តីសម្រេចចិត្ត និងអ្នកគ្រប់គ្រងនៅថ្នាក់ជាតិ ដើម្បីចូលរួមក្នុងការគ្រប់គ្រងធនធានធម្មជាតិតាមបែបសមាហរណកម្ម។ នៅថ្នាក់ខេត្ត ស្ត្រីកំពុងត្រូវបានលើទឹកចិត្តឱ្យចូលរួមក្នុងកិច្ចពិភាក្សា ទាក់ទងនឹងការគ្រប់គ្រងធនធានធម្មជាតិ តាមបែបសមាហរណកម្ម និងចូលរួមក្នុង វគ្គបណ្តុះបណ្តាលបង្កើនចំណេះដឹង និងសកម្មភាពអប់រំផ្សេងៗ។

**២២. សមត្ថភាពអនុវត្តគម្រោង** (តើក្រសួងមានជំនាញនិងបទពិសោធន៍គ្រប់គ្រាន់សម្រាប់អនុវត្តគម្រោងដែរឬទេ?)

**២៣. ស្ថានភាពនៃការអនុវត្តគម្រោង** (ពិពណ៌នាសង្ខេបអំពីវឌ្ឍនភាពរបស់គម្រោងនិងបង្ហាញអំពីភាពប្រឈមនានា ដែល បណ្តាលឲ្យមាន ការព្យាពេលក្នុងការអនុវត្តគម្រោង។)

ដោយអនុលោមតាមគោលនយោបាយរបស់មូលនិធិបរិស្ថានពិភពលោក កម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ(UNDP) គឺជាភ្នាក់ងារអនុវត្តន៍គម្រោង ដែលទទួលខុសត្រូវលើការប្រឹក្សាគម្រោងទូទៅ និងលក្ខណៈបច្ចេកទេស ដើម្បីធានាប្រសិទ្ធភាពកម្មវិធីរបស់ GEF និតិវិធី និងប្រសិទ្ធភាពនៃការត្រួតពិនិត្យតាមដាន ក្នុងការសម្រេចបាន សមិទ្ធផល គម្រោង។ ក្រសួងបរិស្ថាន ជាភ្នាក់ងារប្រតិបត្តិគម្រោង ដែលទទួលខុសត្រូវលើការអនុវត្តន៍គម្រោងនៅទីវាល ដោយអនុលោមទៅតាមគោលបំណង សមិទ្ធផល និងសកម្មភាពរបស់គម្រោង ដែលមានចែងក្នុងឯកសារ គម្រោង។ ក្រសួងបរិស្ថាន ក្នុងនាមជាភ្នាក់ងារប្រតិបត្តិគម្រោង មានដែនសមត្ថកិច្ចក្នុងតំបន់ការពារធម្មជាតិ បញ្ញត្តិដោយច្បាប់ ស្តីពីតំបន់ការពារធម្មជាតិ និងជាស្ថាប័នបង្គោលថ្នាក់ជាតិរបស់មូលនិធិបរិស្ថានពិភពលោក អនុសញ្ញាសហប្រជាជាតិស្តីពីជីវៈចម្រុះ អនុសញ្ញាពុំសា និងអនុសញ្ញាសហប្រជាជាតិស្តីពីការប្រែប្រួលអាកាស ធាតុនៅប្រទេសកម្ពុជា។ រចនាសម្ព័ន្ធគ្រប់គ្រងគម្រោង គឺត្រូវបង្កើតឡើងដោយអនុលោមតាមភាពជាម្ចាស់កម្មសិទ្ធិរបស់រដ្ឋ និងបន្សីគ្នាជាមួយការគ្រប់គ្រងស្ថាប័នរបស់រដ្ឋ ដើម្បីធានានិរន្តរភាព និងពង្រីកសមិទ្ធផលរបស់គម្រោង។

សម្មិទ្ធផលសម្រេចបានសំខាន់ៗ របស់គម្រោង ក្នុងឆ្នាំ២០២៣ រួមមាន៖

១. បានបញ្ចប់នូវការសិក្សាវាយតម្លៃពាក់កណ្តាលការអនុវត្តគម្រោង

២. បានបញ្ចប់ការធ្វើបច្ចុប្បន្នភាពគោលការណ៍ណែនាំ ស្តីពីឧបករណ៍បញ្ច្រាបយែឌ័រក្នុងការអភិរក្សជីវៈចម្រុះ និងសេវាកម្មប្រព័ន្ធអេកូឡូស៊ី ទៅក្នុងផែនការមេនៃការប្រើប្រាស់ដីធ្លី

៣. បានបញ្ចប់នូវការសិក្សាវាយតម្លៃបរិមាណធនធានទឹកនៅក្នុងតំបន់ទេសភាពខាងជើងប្រទេសកម្ពុជា

៤. បានបញ្ចប់នូការសិក្សាអំពីមូលដ្ឋាននៃទំនិញពីកសិកម្មអេកូឡូស៊ី និងតម្រូវការរបស់កសិករដើម្បីលើកកម្ពស់ការផ្សារភ្ជាប់រវាងទីផ្សារ និងផលិតផលនៅឡានជាតិភ្នំគូលែន

៥. បានបញ្ចប់នូវការសិក្សាពីតម្រូវការនៃការកសាងសមត្ថភាពស្ថាប័នសម្រាប់ដៃគូអនុវត្តគម្រោង។

**២៤. អាទិភាពរបស់គម្រោង** (បញ្ជាក់ពីការកំណត់អាទិភាពរបស់គម្រោងរបស់ក្រសួង ស្ថាប័ន)

5

**២៥. ការចូលរួមរបស់ដៃគូអភិវឌ្ឍ** (ផ្តល់ព័ត៌មានអំពីដៃគូអភិវឌ្ឍសក្តានុពល ដែលពាក់ព័ន្ធនឹងគម្រោងនេះ)

គម្រោងនេះ គាំទ្រថវិកាដោយមូលនិធិបរិស្ថានពិភពលោក និងមានការចូលរួមបដិភាគពីរាជរដ្ឋាភិបាលកម្ពុជា និងកម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ។

## ផ្នែក ខ ចំណាយរបស់គម្រោងនិងប្រភពហិរញ្ញប្បទាន

*(គិតជាពាន់ដុល្លារអាមេរិក)*

| ចំណាយវិនិយោគ | 2023 | | 2024 | 2025 | 2026 | 2027 | សរុប | ថវិកា |
|---|---|---|---|---|---|---|---|---|
| | ថវិកា | ជាក់ស្តែង | ថវិកា | ប៉ាន់ស្មាន | ប៉ាន់ស្មាន | ប៉ាន់ស្មាន | 2025-2027 | ចរន្ត |
| **ចំណាយប្រតិបត្តិ** | 214.3 | 144.4 | 281.7 | 133.7 | 0.0 | 0.0 | 133.7 | 0.0 |
| | | | | | | | | |
| បៀវត្សរ៍ | 130.3 | 106.1 | 122.5 | 73.4 | 0.0 | 0.0 | 73.4 | 0.0 |
| សម្ភារៈនិងរដ្ឋបាល | 55.6 | 30.1 | 104.3 | 46.0 | 0.0 | 0.0 | 46.0 | 0.0 |
| ផ្សេងៗ | 28.4 | 8.2 | 54.9 | 14.3 | 0.0 | 0.0 | 14.3 | 0.0 |
| | | | | | | | | |
| **ចំណាយមូលធន** | 479.5 | 231.5 | 1,369.8 | 294.2 | 0.0 | 0.0 | 294.2 | 0.0 |
| | | | | | | | | |
| ការសាងសង់ | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| សេវាទីប្រឹក្សា | 143.5 | 72.0 | 242.4 | 95.2 | 0.0 | 0.0 | 95.2 | 0.0 |
| ទព្វសម្ភារៈ | 0.0 | 0.0 | 3.4 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| ការបណ្តុះបណ្តាល | 46.5 | 5.9 | 84.3 | 38.4 | 0.0 | 0.0 | 38.4 | 0.0 |
| ផ្សេងៗ | 289.5 | 153.6 | 1,039.7 | 160.6 | 0.0 | 0.0 | 160.6 | 0.0 |
| | | | | | | | | |
| **ចំណាយសរុប** | 693.8 | 375.9 | 1,651.5 | 427.9 | 0.0 | 0.0 | 427.9 | 0.0 |
| | | | | | | | | |

| ប្រភពហិរញ្ញប្បទាន | 2023 | | 2024 | 2025 | 2026 | 2027 | សរុប | |
|---|---|---|---|---|---|---|---|---|
| | ថវិកា | ជាក់ស្តែង | ថវិកា | ថ៉ាន់ស្មាន | ថ៉ាន់ស្មាន | ថ៉ាន់ស្មាន | 2025-2027 | |
| | | | | | | | | |
| ចំណូលពីគម្រោង | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | |
| | | | | | | | | |
| ថវិកាជាតិ | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | |
| | | | | | | | | |
| សាច់ប្រាក់សុទ្ធ | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | |
| ធនធានផ្សេងៗ | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | |
| | | | | | | | | |
| ហិរញ្ញប្បទាន របស់ ដៃគូអភិវឌ្ឍ | 693.8 | 375.9 | 1,651.5 | 427.9 | 0.0 | 0.0 | 427.9 | |
| | | | | | | | | |
| Global Environment Facility | 693.8 | 375.9 | 1,651.5 | 427.9 | 0.0 | 0.0 | 427.9 | |
| | | | | | | | | |
| សរុបហិរញ្ញប្បទាន ដែលបានសន្យាផ្តល់ | 693.8 | 375.9 | 1,651.5 | 427.9 | 0.0 | 0.0 | 427.9 | |
| | | | | | | | | |
| តម្រូវហិរញ្ញប្បទាន បំពេញបន្ថែម | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | |

**បានឃើញ និង ឯកភាព**

**រដ្ឋមន្ត្រី**

កាលបរិច្ឆេទ: